**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ១៨៥.....សហវ.ប្រក

# ប្រកាស
## ស្តីពី
## អភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែល ប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញ បន្ថែម និង ការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សំរេច

## ជំពូក ១ : បទប្បញ្ញត្តិទូទៅ

**ប្រការ ១ :** ប្រកាសនេះអនុវត្តចំពោះគ្រប់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ក្រុមហ៊ុនធានារ៉ាប់រងបន្ត ឬ សាខាក្រុមហ៊ុនធានារ៉ាប់រងបរទេស និងសាខាក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេស ដែលបានទទួលការអនុញ្ញាតអោយធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតដល់ប្រភពនៃកម្មសិទ្ធិ ។

**ប្រការ ២ :** ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ មិនត្រូវតែងតាំងបុគ្គលណាម្នាក់ជានាយក ឬ ជានាយកប្រតិបត្តិរបស់ក្រុមហ៊ុននោះទេ ប្រសិនបើមិនមានការឯកភាពជាលាយលក្ខណ៍អក្សរជាមុនពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

នៅក្នុងប្រកាសនេះ ពាក្យថា "នាយក" សំដៅដល់បុគ្គលដែលកាន់មុខដំណែងជា នាយក រួមទាំងបុគ្គលដែលមានអំណាចឋានានុក្រមលើនាយកនោះ ។ រីឯនាយកប្រតិបត្តិសំដៅលើបុគ្គលមួយរូប ឬបុគ្គលមួយក្រុមដែលទទួលការតែងតាំងពីក្រុមប្រឹក្សាភិបាល ក្នុងការទទួលខុសត្រូវគ្រប់គ្រងអាជីវកម្ម និងអង្គភាពនោះ ។

## ជំពូក ២ : លក្ខណៈវិនិច្ឆ័យ «សមស្រប»

**ប្រការ ៣ :** ការតែងតាំងបុគ្គលណាម្នាក់ ដើម្បីឱ្យកាន់តំណែងជានាយក នាយកប្រតិបត្តិ ឬ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ «សមស្រប» ដូចខាងក្រោម :

ក) សុចរិតភាព សមត្ថភាព និងសុភវិនិច្ឆ័យក្នុងការបំពេញភារកិច្ច និងការទទួលខុសត្រូវលើមុខតំណែង

ខ) ការយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ច

គ) ការពិនិត្យលើលក្ខខណ្ឌថា តើការចូលកាន់តំណែងរបស់គាត់ អាចជាការគម្រាមដល់ផលប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកទាមទារសំណងធានារ៉ាប់រង អតិថិជន និង ឥណទាយករបស់ក្រុមហ៊ុនធានារ៉ាប់រងនោះ ដែរឬទេ ?

**ប្រការ ៤ :** លក្ខណៈសម្បត្តិដោយឡែកសំរាប់ នាយកដូចខាងក្រោម :

១- ប្រវត្តិនៃការសិក្សា និងបទពិសោធន៍ការងារ ដែលធានាឱ្យបុគ្គលនោះអាចបំពេញភារកិច្ចបានប្រកបដោយប្រសិទ្ធភាព ។

២- មិនធ្លាប់ធ្វើអ្វីដែលបង្ហាញនូវការសង្ស័យ លើភាពសមស្របរបស់គាត់ក្នុងការកាន់មុខតំណែងជានាយក ។

៣- ត្រូវយល់ព្រមចូលរួម ឬ បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនធានារ៉ាប់រង នោះយ៉ាងតិច ៧៥ភាគរយ ក្នុងមួយឆ្នាំ ហើយក្នុងករណីអវត្តមាន ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៤- មិនធ្លាប់ប្រើសកម្មភាព ឬការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ទៅធ្វើឱ្យខូចប្រយោជន៍ដល់ក្រុមហ៊ុនធានារ៉ាប់រងនោះ និង ធ្វើឱ្យខូចប្រយោជន៍ដល់អ្នកប្រើប្រាស់ ។

**ប្រការ ៥ :** លក្ខណៈសម្បត្តិដោយឡែកសំរាប់ នាយកប្រតិបត្តិ ឬ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ដូចខាងក្រោម :

១- មានប្រវត្តិនៃការសិក្សានិងបទពិសោធន៍ការងារ ដែលធានាអោយបុគ្គលនោះអាចបំពេញតួនាទី និងការទទួលខុសត្រូវបានត្រឹមត្រូវ ។

២- មិនធ្លាប់កាន់តំណែងនៅក្នុងគណៈគ្រប់គ្រងនៃក្រុមហ៊ុនណាមួយ ដែលប្រព្រឹត្តល្មើស នឹងច្បាប់នៅពេលខ្លួនកាន់មុខតំណែង ហើយបើសិនដូចក្នុងករណីនេះ សាមីជនត្រូវបង្ហាញថា គាត់មិនបានដឹងឮ ឬមិនបានឯកភាពចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់នោះឡើយ ឬ ការ ប្រព្រឹត្តិនោះមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់គាត់ ។

៣- មិនធ្លាប់បានកាន់តំណែងនៅក្នុងគណៈគ្រប់គ្រងនៃក្រុមហ៊ុនណាមួយ :

ក) ដែលមិនបានទូទាត់ប្រាក់សំណង ឬបំណុល ដែលសំរេចដោយសាលក្រមរបស់តុលាការ

ខ) ដែលបានពន្យារការទូទាត់បំណុល ឬបង្កការលំបាកដល់ម្ចាស់បំណុល

គ) ដែលមានការតែងតាំងដោយអំណាចសាលក្រមរបស់តុលាការ នូវអ្នកទទួល ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ។

៤- ត្រូវមានលទ្ធភាពធ្វើការពេញម៉ោង ហើយមិនត្រូវមានមុខរបរ ឬធុរៈកិច្ចផ្សេងទៀតឡើយ លើកលែងតែជានាយកមិនប្រតិបត្តិ ឬ ជាភាគទុនិករបស់ក្រុមហ៊ុនផ្សេងទៀត។

៥- មិនមានមុខដំណែងដឹកនាំ ឬ មុខដំណែងដែលនាំអោយមានការទទួលខុសត្រូវនៅក្នុងគណៈបក្សនយោបាយណាមួយ ។

៦- មិនធ្លាប់បង្កស្ថានភាពទំនាស់ផលប្រយោជន៍ ជាមួយក្រុមហ៊ុន ទោះបីដោយខ្លួនផ្ទាល់ ឬ តាមរយៈស្វាមី ភរិយា បុត្រាបុត្រី មាតាបិតា ឬ បងប្អូនក៏ដោយ។

៧- មិនធ្លាប់ធ្វើអ្វីដែលបង្ហាញនូវការសង្ស័យលើភាពសមស្របរបស់គាត់ ក្នុងការកាន់តំណែងជានាយកប្រតិបត្តិ ឬ អ្នកគ្រប់គ្រង ឬការធ្វេសប្រហែសចំពោះក្រមសីលធម៌វិជ្ជាជីវៈជាពិសេស ក្នុងទំនាក់ទំនងជាមួយម្ចាស់បណ្ណសន្យារ៉ាប់រង និង អតិថិជន។

៨- មិនធ្លាប់ប្រើសកម្មភាព ឬការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ទៅធ្វើឱ្យខូចប្រយោជន៍ដល់ក្រុមហ៊ុនធានារ៉ាប់រងនោះ និង ធ្វើឱ្យ

ខូចប្រយោជន៍ដល់អ្នកប្រើប្រាស់ ។

**ប្រការ ៦ :** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានអំណាចឆន្ទានុសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យកំណត់ថាតើបុគ្គលណាម្នាក់ ដែលបានបំពេញនូវលក្ខខណ្ឌខាងលើ ។

## ជំពូក ៣ : កំហិតលើសមាសភាពរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន

**ប្រការ ៧ :**

១- ប្រធានក្រុមប្រឹក្សាភិបាល គឺជាមុខតំណែងមិនប្រតិបត្តិ ។

២- ក្រុមប្រឹក្សាភិបាល ត្រូវមាននាយកឯករាជ្យមិនប្រតិបត្តិចំនួនពីររូបយ៉ាងតិច ។ នាយកឯករាជ្យគឺជាបុគ្គលដែលតំណាងឱ្យផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងផលប្រយោជន៍របស់ភាគទុនិកដែលមិនមានតួនាទីគ្រប់គ្រង ។ នាយកឯករាជ្យមិនត្រូវស្ថិតក្នុងករណីដែលបានរៀបរាប់ដូចខាងក្រោមៈ

ក) កាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលលើសពី ប្រាំ (៥)ភាគរយ នៅក្នុងក្រុមហ៊ុនធានារ៉ាប់រងនោះ ឬ ក្រុមហ៊ុនពាក់ព័ន្ធ ។

ខ) មានតំណែងជានាយកប្រតិបត្តិនៅក្រុមហ៊ុនធានារ៉ាប់រងនោះ ឬក្រុមហ៊ុនពាក់ព័ន្ធក្នុងរយៈពេលតិចជាង ពីរ (២)ឆ្នាំ គិតមកដល់ថ្ងៃតែងតាំង។

គ) មានសមាជិកនៅក្នុងបន្ទុកគ្រួសារ ដែលបាន និងកំពុងធ្វើជានិយោជិកនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងនោះ ឬ ក្រុមហ៊ុនពាក់ព័ន្ធ នៅក្នុងរយៈពេលពីរ(២)ឆ្នាំកន្លងទៅ។

ឃ) ធ្លាប់បានធ្វើជាទីប្រឹក្សាឱ្យក្រុមហ៊ុនធានារ៉ាប់រងនោះ ឬ ក្រុមហ៊ុនពាក់ព័ន្ធនៅក្នុងរយៈពេល ពីរ (២)ឆ្នាំកន្លងទៅ។

ង) ធ្លាប់បានធ្វើប្រតិបត្តិការជំនួញដែលមានចំនួនទឹកប្រាក់លើសពី ២៨០ លានរៀល ជាមួយក្រុមហ៊ុនធានារ៉ាប់រងនោះ នៅក្នុងរយៈពេល ពីរ(២)ឆ្នាំកន្លងទៅ។

៣- តួនាទី និងការទទួលខុសត្រូវរបស់នាយកឯករាជ្យ មានដូចខាងក្រោម :

ក- សំរបសំរួលរាល់បញ្ហានៃដំណើរការគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង

ខ- ចូលរួមប្រកបដោយការស្ថាបនា ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្ររបស់ក្រុមហ៊ុននោះ

គ- ធានាមុខងារត្រួតពិនិត្យតម្លាភាពរបស់ក្រុមប្រឹក្សាភិបាល

ឃ- វាយតំលៃលើលទ្ធផលនៃការសំរេចគោលដៅរបស់ក្រុមហ៊ុនធានារ៉ាប់រង អោយបានត្រឹមត្រូវ

## ជំពូក ៤ : គណៈកម្មការសវនកម្ម

**ប្រការ ៨ :**

១- គោលបំណងចំបងនៃគណៈកម្មការសវនកម្មគឺជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការអនុវត្ត

ភារកិច្ច និងការទទួលខុសត្រូវ ដែលទាក់ទងនឹងភាពត្រឹមត្រូវ និង តម្លាភាពនៃការត្រួតពិនិត្យរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ និងប្រព័ន្ធរាយការណ៍របស់ក្រុមហ៊ុន។

២- គណៈកម្មការសវនកម្ម ត្រូវអនុវត្តភារកិច្ចជាពិសេសដូចខាងក្រោម :

ក) ត្រួតពិនិត្យ និង វាយតម្លៃគុណភាពសវនកម្ម ដែលធ្វើឡើងដោយសវនករផ្ទៃក្នុង និង សវនករឯករាជ្យ ។

ខ) ធានាឱ្យមានការប្រាស្រ័យទាក់ទង និងការពិគ្រោះពិភាក្សារវាងក្រុមប្រឹក្សាភិបាល សវនករផ្ទៃក្នុង សវនករឯករាជ្យ និង គណៈគ្រប់គ្រង ។

គ) វាយតម្លៃភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យរដ្ឋបាល ប្រតិបត្តិការ និង គណនេយ្យ ហើយនិងភាពត្រឹមត្រូវនៃពតិមានហិរញ្ញវត្ថុ ។

**ប្រការ ៩ :**

១- គណៈកម្មការសវនកម្មត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាលពីក្នុងចំណោមនាយកផ្សេងៗ របស់ក្រុមហ៊ុន ហើយត្រូវមានសមាជិកយ៉ាងតិចចំនួនបី(៣)រូប ដែលសមាជិកភាគច្រើនត្រូវជានាយកឯករាជ្យ ។

២- សមាជិកគណៈកម្មការសវនកម្មមិនត្រូវកាន់តំណែងប្រតិបត្តិនៅក្នុងក្រុមហ៊ុនធានារ៉ាប់រង ឬ ក្រុមហ៊ុនពាក់ព័ន្ធ និង មិនត្រូវមានទំនាក់ទំនងណាមួយ ដែលអាចធ្វើឱ្យបាត់បង់សុភវិនិច្ឆ័យឯករាជ្យក្នុងការអនុវត្តន៍មុខងាររបស់គណៈកម្មការសវនកម្ម តាមរយៈការលើកមតិយោបល់ នៅក្នុងក្រុមប្រឹក្សាភិបាល ។

៣- សមាជិកគណៈកម្មការសវនកម្ម មិនត្រូវមានការទទួលខុសត្រូវដោយផ្ទាល់ ឬដោយផ្អែកលើមុខងារគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រងឡើយ ។

៤- សមាជិកទាំងឡាយរបស់គណៈកម្មការសវនកម្ម ត្រូវបោះឆ្នោតជ្រើសរើសប្រធានក្នុងចំណោមសមាជិករបស់ខ្លួន ដែលប្រធានជាប់ឆ្នោតដាច់ខាតត្រូវតែជានាយកឯករាជ្យ និង មិនប្រតិបត្តិ ។

៥- ក្រុមប្រឹក្សាភិបាល ត្រូវពិនិត្យឡើងវិញនូវលក្ខខណ្ឌរបស់សមាជិកគណៈកម្មការសវនកម្ម យ៉ាងតិចរៀងរាល់ពីរ (២)ឆ្នាំម្តង ។

## ជំពូក ៥ : អទសានបញ្ញត្តិ

**ប្រការ ១០ :**

១- បុគ្គលណាដែលប្រព្រឹត្តល្មើស ឬមិនបានបំពេញតាមបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ចំនួន ១០ លានរៀល ក្នុងរយៈពេលពីរ (២)សប្តាហ៍ បង់ចូលរតនាគារជាតិ តាមដីការអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។

២- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចផ្តល់រយៈពេលសមស្របមួយ ដើម្បីឱ្យក្រុមហ៊ុន ដែលទទួលអាជ្ញាប័ណ្ណបំពេញបានតាមបទប្បញ្ញត្តិនានានៃប្រកាសនេះ បន្ទាប់ពីមានពាក្យស្នើសុំជាក់លាក់ណាមួយ ។

**ប្រការ ១១ :** រាល់បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១២ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- ឯកសារ-កាលប្បវត្តិ